**SPRING PARKS PRIMARY SCHOOL**

*Learning and Growing - Safety - Together*

**West Campus - Administration**
24 Erica Street, Springvale 3171 ☎ 9546 6402

**Valley Campus**
27-39 Clarke Road, Springvale South 3172 ☎ 9547 3222

spring.parks.ps@education.vic.gov.au






ជំរាបមាតាបិតា/អាណាពាបាល,

## អគ្គនាយកសាលា:

បានចាប់ផ្តើមធ្វើការនៅសាលាយើងនាថ្ងៃអង្គារទី២៦មេសា។ អ្នកគ្រូជាអគ្គនាយកថ្មី,ហើយខ្ញុំសូមស្វាគមន៏អ្នកគ្រូមកសាលាយើង។ នៅត្រីមាសទី២,អ្នកគ្រូតាំងមូលដ្ឋាននៅសាខាវ៉ាល្លី,តែយូរៗនឹងមកសាខាខាងលិចដើម្បីជួបទាក់ទងសិស្សានុសិស្ស , បុគ្គលិកនិងគ្រួសារទាំងឡាយ។ សូមសម្តែងភាពស្វាគមន៏នៅពេលជួបអ្នកគ្រូរាល់ព្រឹកនៅមាត់ទ្វារសាលា។

## ថ្ងៃថតរូបសាលា:

ថ្ងៃព្រហស្បតិ៏ទី១៩//៥ជាថ្ងៃថតរូបសាលាសំរាប់សាខាទាំងពីរ។សូមឲ្យកុមារស្លៀកពាក់ឯកសណ្ឋានសាលាត្រឹមត្រូវក្នុងថ្ងៃនេះ។ជាងថតរូបនិយមឲ្យគ្រួសារបញ្ជាទិញរូបថតតាមរយ:អ៊ិនធើណែត,ក៏ប៉ុន្តែមាតាបិតាអាចបង់ប្រាក់នៅការិយាល័យផងដែរឬបង់តាមរយ: កាតទិញជឿ(credit card)ដោយបញ្ចូលពត៏មាននៃកាតនេះនៅក្នុងស្រោមសំបុត្រដែលសាលាផ្ញើទៅផ្ទះកាលពីសប្តាហ៏មុន។សូមយកចិត្តទុកដាក់មើលក្នុងកាបូបរបស់កុមារ។

## កំណត់ប្រចាំថ្ងៃ:២/៥/២០២២

០៣/៥: Playgroup នៅសាខាខាងលិចពីម៉ោង ៩-១១ព្រឹក
រៀនអំពីសុវត្ថិភាពក្នុងការប្រើអ៊ិនធើណែតសំរាប់កុមារសាលាទាំងមូលនៅសាខាវ៉ាល្លី

០៤/៥: តូបលក់ឥវ៉ាន់សំរាប់ថ្ងៃមាតា:ម៉ោង១១:០០
Amazing Race: ព្រឹត្តិការណ៏សហគមន៏ នៅសាខា វ៉ាល្លី:ម៉ោង៤:០០ល្ងាច
ពេល;រៀនអំពីសុវត្ថិភាពក្នុងការប្រើអ៊ិនធើណែតសំរាប់មាតាបិតានៅម៉ោង៧:៣០

០៥/៥: តូបលក់ឥវ៉ាន់សំរាប់ថ្ងៃមាតា:ម៉ោង១១:០០

០៦/៥: គោរពទង់ជាតិនៅម៉ោង៣:០០

១០/៥: ប្រឡងសាកNAPLAN សំរាប់ថ្នាក់ទី៣និង៥

១១/៥: ប្រឡងសាក NAPLAN
ថ្នាក់មូលដ្ឋានដំណើរសិក្សានៅWoodleigh

១២/៥: ប្រឡងសាក NAPLAN

១៣/៥: គោរពទង់ជាតិនៅម៉ោង៣:០០ល្ងាច

## តូបលក់ឥវ៉ាន់សំរាប់ថ្ងៃមាតា

សាលានឹងចាត់ចែងតូពលក់ឥវ៉ាន់សំរាប់ថ្ងៃមាតានៅសាខាទាំងពីរនៅថ្ងៃពុធ ទី៤/៥ និងថ្ងៃព្រហស្បតិ៏ទី៥/៥។បានទីញឥវ៉ាន់ដ៏ល្អៗមួយចំនួនសំរាប់ឲ្យកុមារទិញក្នុងតម្លៃពី$១-$២ ដល់$១០។តូបលក់ឥវ៉ាន់នឹងចាប់បើកលក់នៅសាខាខាងលិចពីម៉ោង១១-១១:៣០ព្រឹកនៅថ្ងៃទាំងពីរ។សាខាវ៉ាល្លីនឹងលក់នៅក្នុងអគ្គា LEC ពីម៉ោង១១:០០-១១:៣០ព្រឹក។សូំរំឭកកូនចៅលោកអ្នកឲ្យយកប្រាក់មកជាមួយដើម្បីទិញឥវ៉ាន់។

## សុវត្ថិភាពក្នុងការប្រើអ៊ិនធើណែត

សិស្សទាំងឡាយនឹងចូលរួមក្នុងវគ្គរៀនអំពីសុវត្ថិភាពក្នុងការប្រើអ៊ិនធើណែតនៅថ្ងៃអង្គារទី៣/៥។ក្នុងពេលរៀននិមួយៗមានរយ:ពេល៧៥នាទី។យើងខ្ញុំមានអ្នកជំនាញការមួយចំនួននៅសាលាក្នុងថ្ងៃនេះ។សាលាក៏មានវគ្គរៀនសំរាប់មាតាបិតានិងគ្រួសារដែលនឹងប្រព្រឹត្តទ្បើងតាមរយ: អ៊ិនធើណែតនៅថ្ងៃពុធទី៤/៥។ពត៏មានពិស្តារអំពីការចូលរៀននឹងមាននៅប៉ែកខាងក្រោយនៅប័ណ្ណពត៏មាននេះ។

## ក្រុមប្រឹក្សាសាលាឆ្នាំ២០២២:

ខ្ញុំសូមប្រកាសជូនដល់សហគមន៏សាលាយើងចំពោះនាមនៃសាមាជិកក្រុមប្រឹក្សាសាលាឆ្នាំ២០២២ដូចតទៅ:

Jolita Curcio – លេលេខាធិការកត់សេចក្តី
Simone Beveridge – ម្តាយរបស់ Tyler
Pheaktea Pich – ឪពុករបស់ Morokot & Eren
Shirley Huynh – ម្តាយរបស Edward
Rotana Sok – ម្តាយរបស់ Kieran, Darrean & Honeyrose
Crystal Moon – ម្តាយរបស់ Luke

បើមាតាបិតាមានបញ្ហាចង់លើកយកមកពិគ្រោះនៅក្រុមប្រឹក្សាសាលា,សូមទាក់ទងនឹងសមាជិកដែលមាននាមនៅខាងលើ។ ខ្ញុំសូមអរគុណដល់សមាជិកថ្មីទាំងឡាយដែលស្ម័គ្រចិត្តទទួលមុខតំណែងនេះនៅសាលាយើង,ព្រោះពុំមានសាលាណាអាចមានដំណើរការណ៏បានដោយពុំមានក្រុមប្រឹក្សានោះទ្បើយ,ហើយសំខាន់ជាងនេះទៅទៀតគឺសំរាប់ឲ្យគ្រួសារទាំងឡាយមាន"សម្លេង "ចំពោះកិច្ចការទាក់ទងនឹងសាលាយើង។

Julie Fisher

នាយកសាលា

**សាលាយើងមានក្តីសោមនស្សជាគូរភាគីនឹង : Ardoch, IKEA, Woodleigh School, Officeworks & Resilience Project**

# កាលវិភាគនៃការប្រឡងសាក NAPLAN

ខាងក្រោមនេះជាតារាងកាលវិភាគនៃការប្រឡងសាកតាមរយៈអ៊ិនធើណែតសំរាប់ថ្នាក់ទី៣និង៥។តារាងនៃការប្រឡងមានដូចតទៅ :

| | | |
|---|---|---|
| ថ្ងៃអង្គារ,ទី១០/៥ | 9.30 a.m. ប្រឡងសរសេរ | |
| ថ្ងៃពុធទី១១/៥ | 9.30 a.m. ប្រឡងអាន | ម៉ោង 12.00ព្រឹក ប្រឡងខាងភាសារ (ប្រកបពាក្យ,វេយ្យករណ៏) |
| ថ្ងៃព្រហស្បត៏ទី ១២/៥ | 9.30 a.m. ប្រឡងលេខ | |

ការប្រឡងទាំងឡាយនឹងប្រព្រឹត្តឡើងតាមរយៈអ៊ិនធើណែតដោយ ប្រើកុមព្យូទ័រសាលា,លើកលែងការប្រឡងខាងសរសេរនៃថ្នាក់ទី៣ នៅសរសេរលើក្រដាស់។

លំដាប់នៃការប្រឡងរៀបចំដោយក្រសួងអប់រំហើយកាលវិភាគនេះមិនអាចផ្លាស់ប្តូរបាន។សូមមាតាបិតាទុកចិត្តថា,ការប្រឡងសាកនេះគឺជាមធ្យោបាយមួយដើម្បីយកពត៌មានពីសិស្សនិមួយៗ,ហើយយើងខ្ញុំប្រើពត៌មាននេះជាមួយគ្នានឹងទំរង់នៃការប្រឡងនានាក្នុងសាលា។

សិស្សនិមួយៗនឹងបានទទួលរបាយការណ៏ពីការប្រឡងនេះសង្ឃឹមថា នៅចុងត្រីមាសទី២។របាយការណ៏នេះនឹងផ្ញើមកសាលា,ហើយយើងខ្ញុំនឹងផ្ញើទៅផ្ទះជូនក្នុងថ្ងៃរបាយការណ៏នេះមកដល់។បើលោកអ្នកត្រូវការចង់ដឹងពត៌មានបន្ថែមអំពីការប្រឡងសាកនេះ(NAPLAN)សូមទាក់ទងនឹងគ្រូរបស់កុមារ,ឬទូរស័ព្ទមកការិយាល័យសាលាឬនិយាយជាមួយMrs Fisher.

## រៀនលេងតន្ត្រីនៅសាលា

**សូមអញ្ជើញមករួមសប្បាយក្នុងការរៀនគ្រឿងតន្ត្រីដូចជា Keyboard, ហ្គីតា (guitar), Ukulele នៅសាលាបឋមសិក្សា ស្ព្រីងប៉ាក**

ក្រុមហ៊ុន Creative Music បានរៀបរាងកម្មវិធីរៀនតន្ត្រីសំរាប់កុមារសាលាជាក្រុមតូចៗ ឬ១ទល់១ ក្នុងសាលារាល់សប្តាហ៏ក្នុងរយៈពេល៣០នាទី។ គោលដៅរបស់យើងគឺផ្តល់ឲ្យកុមារនូវមូលដ្ឋានរឹង ប៉ឹងខាងតន្ត្រី។ កុមារនឹងរៀនមើលសញ្ញាតន្ត្រីហើយលេងឧបករណ៏តន្ត្រីតាមជំរើសរបស់ខ្លួន។

ការទទួលឈ្មោះរៀន់សំរាប់ត្រីមាសទី២,ឆ្នាំ ២០២២បានចាប់ផ្តើមហើយ។

ប្រសិនជាមាតាបិតាប្រាថ្នាឲ្យកូនចៅក្នុងគ្រួ សារមករៀន,សូមទាក់ទងនឹង Swee ក្នុង ពេលធ្វើការ–តាមទូរស័ព្ទ:98182333 ឬតាមគេហទំព័រ :

www.creativemusic.com.au



## សាលាមត្តេយ្យដ្ឋានស្ព្រីងវ៉ាល្លី

## (Springvalley kindergarten)

**Springvalley kindergarten**

ឥឡូវនេះទទួលកុមារអាយុពី៣ឆ្នាំឲ្យមករៀន។សាលានេះនៅមានកន្លែងសំរាប់ឆ្នាំ ២០២២។ បើមាតាបិតាមានកូនអាយុគ្រប់៣ឆ្នាំគិតដល់ថ្ងៃទី៣០/៨/២០២២, សូមមកជួបរ៉ូស៊ី(Rosy )ដើម្បីចុះឈ្មោះ។

សាលាបឋមសិក្សាស្ព្រីងប៉ាក ( Spring Parks Primary School )ឥឡូវនេះចាប់ផ្តើមទទួលឈ្មោះសំរាប់ឆ្នាំសិក្សា២០២៣ហើយ។

CYBER SAFETY PROJECT

LIVE WEBINAR SESSION FOR PARENTS

# រៀនសូត្រ,ទំនាក់ទំនងហើយលេងដោយសេចក្ដីសុខលើអ៊ិនធើណែត

## ថ្ងៃពុធ ទី៨ ខែ ៥ ឆ្នាំ២០២២, ម៉ោង ៧:៣០-៨:៤៥យប់

### ទិដ្ឋភាពជាទូរទៅនៃការរៀនតាមអ៊ិនធើណែតសំរាប់មាតាបិតានិងអាណាព្យបាល

កុមារក្នុងសម័យនេះចូលចិត្តលេង,ទាក់ទងនឹងមិត្តភក្តិហើយរៀនសូត្រតាមអ៊ិនធើណែត។វគ្គរៀននេះមានគោលបំណងផ្តល់ឲ្យមាតាបិតានិងអាណាព្យាបាលការយល់ដឹងជ្រៅជ្រះនិងពត៏មានអំពីបទពិសោធន៏សំខាន់ៗនៃអ៊ិនធើណែតដែលកុមារជួបប្រទះក្នុងសម័យនេះ។ស្ថាបនាបរិយាកាសដ៏សុខសាន្តហើយរុងរឿងក្នុងគ្រួសារដោយប្រើបច្ចេកទេសលេខជាអំពើមួយគួរឲ្យលើកទឹកចិត្ត,តែធ្វើដូច ម្ដេចដើម្បីត្រួតពិនិត្យឲ្យមាននប្រសិទ្ធភាព,គឺជាជាកិច្ចការមួយយ៉ាងពិបាក។តាមរយៈការរៀនដោយអ៊ិនធើណែត,ក្រុមគំរោងសុវត្ថិភាពអ៊ិនធើណែតបានលើកយកបង្ហាញផ្នែកសំខាន់ៗពីការរៀបរាងកំណត់នៃវិធីប្រើហើយនឹងផ្នែកសំរាប់ឲ្យមាតាបិតាត្រួតពិនិត្យការរាវរកលើអ៊ិនធើណែតរបស់កុមារលើអ៊ិនធើណែតដោឯកឯងតែក្នុងសុវត្ថិភាព។លោកអ្នកនឹងបានបង្ហាញឲ្យឃើញសម្ភារៈដែលបានរៀបចំទុកជាស្រេចព្រមទាំងវិធានការណ៏នានាសំរាប់បង្កើតការចេះដឹងសំខាន់ៗអំពីសុខមាលភាពនិងសុវត្ថិភាពខាងបច្ចេកទេសលេខសំរាប់កុមារ នៅផ្ទះ,ដែលក្នុងនោះមានរួមទាំងការស្វែងរកជំនួយបើមានឧប្បត្តិហេតុកើតឡើងក្នុងពេលប្រើអ៊ិនធើណែត។

### តើលោកអ្នកនឹងរៀនអំពីអ្វី ?

- គំរោងអំពីសុវត្ថិភាពអ៊ិនធើណែត
- បណ្ដាញសង្គមកំពុងពេញនិយមហើយនឹងការត្រួត្រួតពិនិត្យចំពោះទំនាក់ទំនងមិនត្រូវការ។
- ល្បែងលេងអេឡិចត្រូនិកកំពុងពេញនិយមនិងតំណាណែនាំឆ្ពោះទៅលេងល្បែងស៊ីសង ។
- រៀបចំដោយឡែកបច្ចេកទេសសំរាប់ឱពុកម្ដាយត្រួតពិនិត្យហើយនឹងកម្មវិធីនានា
- ការគំរាមគំហែងក្នុងអ៊ិនធើណែតហើយនឹងវិធានការស្វែងរកជំនួយ
- ស្ថានាហើយរក្សាបរិយាកាសប្រើអ៊ិនធើណែតដ៏សុខសាន្តក្នុងផ្ទះ

### រៀបរាងចាត់ចែងដោយ

THE CYBER SAFETY PROJECT



**SAM MACAULAY**
Lead Cyber SafetyEducator



**TRENT RAY**
Educator & MicrosoftLearning Consultant

*Cyber Safety Project is a Certified Provider by the Office of the eSafety Commissioner*

trusted eSafetyprovider
esafety.gov.au

THE AMAZING RACE



ពេលល្ងាចដ៏រីករាយមួយសំរាប់គ្រួសារទាំងមូល

កុមារចូលរួមជាក្រុមជាមួយនឹងឪពុកម្តាយរបស់ខ្លួន
ដើម្បីស្វែងរកកំណាប់។

ថ្ងៃពុធ ទី១៨ ឧសភា

សាខាវ៉ាល្លី

ពីម៉ោង៤ ដល់ ម៉ោង ៥- ល្បែងរកកំណាប់

ពីម៉ោង៥ ដល់ ម៉ោង ៦ល្ងាច-

សាច់ក្រកអាំងជូនដោយឥតគិតថ្លៃ



ត្រូវឆ្នោតវត្ថុ

សប្បាយរីករាយ